**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
* * * * * *

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**
* * * * * *

នៅរសៀលថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៩ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានអនុញ្ញាតឲ្យលោកជំទាវ Heather Wheeler អនុរដ្ឋលេខាធិការសភា និងជារដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការអាស៊ី និងប៉ាស៊ីហ្វិក នៃក្រសួងការបរទេសចក្រភពអង់គ្លេស ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ។ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី បានសម្តែងការអបអរសាទរ ចំពោះការកាន់មុខតំណែងថ្មីនេះរបស់លោកជំទាវ និងបានសំដែងការស្វាគមន៍យ៉ាងកក់ក្តៅចំពោះដំណើរទស្សនកិច្ចជាលើកដំបូងរបស់លោកជំទាវមកកាន់កម្ពុជា ដែលនឹងជួយពង្រឹងបន្ថែមទៀតនូវចំណងមិត្តភាពនិងកិច្ចសហប្រតិបត្តិការរវាងកម្ពុជានិងចក្រភពអង់គ្លេស។

**ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** បានសំដែងការពេញចិត្តចំពោះកិច្ចសហប្រតិបត្តិការល្អប្រសើរ រវាងប្រទេសទាំងពីរ ដែលឆ្លុះបញ្ចាំងតាមរយៈការផ្លាស់ប្តូរទស្សនកិច្ចកម្រិតខ្ពស់ញឹកញាប់ កំណើនទំហំពាណិជ្ជកម្មទ្វេភាគី រួមនឹងវត្តមានក្រុមហ៊ុនវិនិយោគទុនធំៗជាច្រើនរបស់ចក្រភពអង់គ្លេសនៅកម្ពុជា។ **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** បានកត់សម្គាល់ដោយក្តីរីករាយចំពោះការផ្លាស់ប្តូរពាណិជ្ជកម្មទ្វេភាគីរវាងកម្ពុជានិងអង់គ្លេស ដែលមានទំហំជាង១ប៊ីលានដុល្លារអាមេរិក ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។

**លោកជំទាវ** Heather Wheeler បានវាយតម្លៃខ្ពស់ចំពោះទំនាក់ទំនងរវាងកម្ពុជា និងចក្រភពអង់គ្លេស ហើយសង្ឃឹមថា ទំនាក់ទំនងនេះ នឹងបន្តរីកលូតលាស់បន្ថែមទៀត។ **លោកជំទាវ** បានកត់សម្គាល់ពីការរីកចម្រើនយ៉ាងឆាប់រហ័សផ្នែកសេដ្ឋកិច្ច និងចាប់អារម្មណ៍លើការវិវឌ្ឍថ្មីៗនៃនយោបាយនៅកម្ពុជា។

ចំពោះសភាពការណ៍នយោបាយ **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** បានគូសបញ្ជាក់ថា កន្លងមកនេះ រាជរដ្ឋាភិបាលកម្ពុជា បានចាត់វិធានការផ្លូវច្បាប់ចំពោះគណបក្សនយោបាយបំពានច្បាប់។ នោះគឺជាការអនុវត្តគោលការណ៍នីតិរដ្ឋ ដើម្បីពង្រឹងដំណើការលទ្ធិប្រជាធិបតេយ្យ និងធានាសន្តិភាព ស្ថេភាពនៅក្នុងប្រទេស។ មកដល់បន្ទុប្បន្ននេះ បុគ្គលដែលជាប់បំរាមសកម្មភាពនយោបាយមានសិទ្ធិអាចចាប់ផ្តើមសកម្មភាពនយោបាយរបស់ខ្លួនឡើងវិញទៅតាមច្បាប់។ទន្ទឹមនឹងនោះ សេរីភាពនៃការបញ្ចេញមតិ និងសេរីភាពសារព័ត៌មានត្រូវបានធានា។ កង្វល់នានារបស់អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងបរទេស ត្រូវបានដោះស្រាយជាបន្តបន្ទាប់តាមការរៀបចំវេទិការវាងអាជ្ញាធរពាក់ព័ន្ធ និងអង្គការមិនមែនរដ្ឋាភិបាល។

**ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** បានថ្លែងអំណរគុណចំពោះចក្រភពអង់គ្លេសដែលបានប្រកាសថា នឹងផ្តល់ភាពអនុគ្រោះផ្នែកពាណិជ្ជកម្មដល់ក្រុមប្រទេសដែលមានការអភិវឌ្ឍតិច (LDCs) ៤៨ប្រទេស រួមទាំង

ឥ.

កម្ពុជាផងដែរ នៅពេលដែលចក្រភពអង់គ្លេសចាកចេញផុតពីសហភាពអឺរ៉ុប(Brexit)។ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** ក៏បានវាយតម្លៃខ្ពស់ចំពោះជំនួយជាច្រើនរបស់ចក្រភពអង់គ្លេស ដែលគាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម នៅកម្ពុជា។

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានជំរាបជូនអំពីការត្រៀមលក្ខណៈរបស់កម្ពុជាក្នុងការរៀបចំកិច្ចប្រជុំកំពូលអាស៊ី-អឺរ៉ុប (ASEM) នៅចុងឆ្នាំ២០២០ខាងមុខនេះ ហើយកម្ពុជានិងដាក់ប្រធានបទសំរាប់កិច្ចប្រជុំកំពូលនេះជូនថ្នាក់រដ្ឋមន្ត្រី ASEM នៅទីក្រុងម៉ាឌ្រីត ប្រទេសអេស្ប៉ាញ។ កម្ពុជាសង្ឃឹមថា ឯកឧត្តមនាយករដ្ឋមន្ត្រីអង់គ្លេសនឹងអញ្ជើញចូលរួមកិច្ចប្រជុំកំពូលអាស៊ី-អឺរ៉ុប (ASEM) នៅកម្ពុជា។

ចំពោះទំនាក់ទំនងរវាងអាស៊ាន-ចក្រភពអង់គ្លេស **លោកជំទាវ** Heather Wheeler បានបង្ហាញក្តីសង្ឃឹមថា កម្ពុជានឹងជួយគាំទ្រអង់គ្លេសឲ្យក្លាយជាដៃគូសន្ទនារបស់អាស៊ាន ក្រោយពីចក្រភពអង់គ្លេសចាកចេញពីសហភាពអឺរ៉ុបនាពេលខាងមុខ។ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានឆ្លើយតបជាវិជ្ជមានចំពោះសំណើរបស់**លោកជំទាវ** និងបានវាយតម្លៃខ្ពស់ចំពោះការប្តេជ្ញាចិត្តរបស់ចក្រភពអង់គ្លេស ក្នុងការជំរុញចំណងទាក់ទងជាមួយអាស៊ានឲ្យកាន់តែរឹងមាំ។

ពាក់ព័ន្ធនឹងបញ្ហាតំបន់ **លោកជំទាវ** បានគូសបញ្ជាក់ថា អង់គ្លេសចង់ឃើញការធានាបាននូវសេរីភាពនៃការធ្វើនាវាចរណ៍នៅសមុទ្រចិនខាងត្បូង។ ចំពោះកង្វល់នេះ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានគូសបញ្ជាក់ថា បច្ចុប្បន្ននេះអាស៊ាន និងចិនកំពុងពិភាក្សាលើក្រមប្រតិបត្តិនៃសមុទ្រចិនខាងត្បូងហើយសង្ឃឹមថាក្រមប្រតិបត្តិនេះនិងអនុម័តិនៅក្នុងរយៈពេល៣ឆ្នាំទៀត។ កម្ពុជាមិនមែនជាប្រទេសដែលទាមទារសិទ្ធិអធិបតេយ្យនៅសមុទ្រចិនខាងត្បូងទេ ហើយក៏ពុំមានជំហរលំអៀងទៅរកភាគីណាមួយនៃប្រទេសដែលពាក់ព័ន្ធនោះដែរ។ **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** បានសង្កត់ធ្ងន់ថា អ្វីដែលកម្ពុជាចង់បាន គឺការរក្សាបាននូវសន្តិភាព និងស្ថិរភាពនៅក្នុងតំបន់ និងការដោះស្រាយបញ្ហាសមុទ្រចិនខាងត្បូង ដោយផ្អែកលើគោលការណ៍ច្បាប់អន្តរជាតិ ក្នុងនោះមានច្បាប់សមុទ្រ(UNCLOS) ។

ជំនួបនេះ បានបញ្ចប់ក្នុងបរិយាកាសរីករាយ និងស្និទ្ធស្នាល៕ ✓.

ថ្ងៃព្រហស្បតិ៍ ០៦រោច ខែភទ្របទ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែកញ្ញា ឆ្នាំ២០១៩